បទដ្ឋានការងារក្នុងសង្វាក់ផ្គត់ផ្គង់ជាសកល
គំរោងសកម្មភាពសម្រាប់អាស៊ី និង វិស័យកាត់ដេរ

International Labour Organization

កក្កដា ២០១៥

ព្រឹត្តិបត្រវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើងកម្ពុជា | លេខ ၊

# កំណើននៅតែបន្តសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើងកម្ពុជា

**ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើងកម្ពុជា ដែលគឺជាវិស័យគន្លឹះមួយសម្រាប់សេដ្ឋកិច្ចរបស់ប្រទេស បានបន្តមានដំណើរការល្អក្នុងឆ្នាំ 2014។ ការនាំចេញបានកើនឡើង 9.3 ភាគរយក្នុងឆ្នាំកន្លងទៅ និង បានកើនឡើង 10.6 ភាគរយនៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2015 (ធៀបទៅនឹងត្រីមាសទីមួយនៃឆ្នាំ 2014)។ បច្ចុប្បន្ន វិស័យនេះផ្តល់ការងារដល់កម្មករនិយោជិតប្រហែល 600,000 នាក់ ដែលប្រាក់ឈ្នួលពួកគេបានកើនឡើងយ៉ាងច្រើនក្នុងរយៈពេលពីរឆ្នាំកន្លងទៅនេះ។ ទន្ទឹមនឹងនេះ រោងចក្រមួយចំនួនដែលដំណើរការនៅក្នុងវិស័យនេះ បានកើនឡើងដល់កម្រិតឯតទគ្គៈចំនួន 640 ក្នុងខែ មីនា ឆ្នាំ 2015 ធៀបទៅនឹងចំនួន 528 នៅចុងឆ្នាំ 2013។**

## 1. សេក្តីផ្តើម

ព្រឹត្តិបត្រនេះ ពិនិត្យមើលដំណើរការវិវត្តនៃវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងកម្ពុជា ដោយផ្តោតលើការនាំចេញ ប្រាក់ឈ្នួល ការងារ ការបើកនិងការបិទរោងចក្រ និងការវិនិយោគបរទេសផ្ទាល់ថ្មី។ វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង គឺជាឧស្សាហកម្មផលិតកម្មធំបំផុតនៃប្រទេសកម្ពុជា និង ជាវិស័យរកចំណូលជារូបិយវត្ថុបរទេសធំបំផុតរបស់ប្រទេស។ ព្រឹត្តិបត្រនេះ ចងក្រងជាឯកសារនូវការវិវត្តនៃវិស័យនេះ ដែលត្រូវបានគាំទ្រដោយទិន្នន័យផ្លូវការចុងក្រោយបំផុត ភាគច្រើនគឺបានមកពីក្រសួងពាណិជ្ជកម្ម ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាវិនិយោគកម្ពុជា វិទ្យាស្ថានជាតិស្ថិតិ និង ធនាគារជាតិនៃកម្ពុជា។[1]

## 2. ការនាំចេញសម្លៀកបំពាក់និងស្បែកជើង

ឧស្សាហកម្មកាត់ដេរនិងវាយនភណ្ឌ បានលូតលាស់ប្រហែលពីរទសវត្សរ៍រួចមកហើយ។ កំណើនបានកើនឡើង យ៉ាងខ្លាំងនៅពេលដែលទំនាក់ទំនងពាណិជ្ជកម្មជាធម្មតាជាមួយសហរដ្ឋអាមេរិក និង សហភាពអឺរ៉ុប បានចូលជាធរមាន ក្នុងឆ្នាំ 1996 និង 1997។ ពីការចាប់ផ្តើមដ៏តូចជាមួយការនាំចេញមានតម្លៃ 27 លានដុល្លារក្នុងឆ្នាំ 1995 វិស័យនេះបានកើនឡើង 200 ដង និង មកដល់ដំណាច់ឆ្នាំ 2014 បានផ្តល់ការងារ ជូនដល់យុវជនកម្ពុជាជាងកន្លះលាននាក់ (86 ភាគរយនៃពួកគេគឺជាយុវនារី[2])។

ឧស្សាហកម្មនេះ បានបន្តមានដំណើរការល្អក្នុងឆ្នាំ 2014 ជាមួយចំណូលខ្ពស់បំផុតនៃការនាំចេញនៅក្នុងប្រវត្តិសាស្រ្តរបស់ប្រទេស។ ការនាំចេញសម្លៀកបំពាក់ និងស្បែកជើង បានកើនឡើង 9.3 ភាគរយ ដល់ 5.8 ពាន់លានដុល្លារ ពី 5.3 ពាន់លានដុល្លារកាលពីឆ្នាំមុន។ វិស័យស្បែកជើងមានសក្តានុពល គួរអោយកត់សម្គាល់ដោយមានកំណើននាំចេញ 23.9 ភាគរយ គឺឡើងដល់ 438 លានដុល្លារ ខណៈពេលដែលការនាំចេញនៃវិស័យកាត់ដេរសម្លៀកបំពាក់ បានកើនឡើង 8.3 ភាគរយ គឺឡើងដល់ 5.4 ពាន់លានដុល្លារ។ កំណើនការនាំចេញនៃវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើងក្នុងឆ្នាំ 2014 មានលក្ខណៈថយចុះបន្តិចពីកំណើន 11.8 ភាគរយដែលបានកត់ត្រាក្នុងឆ្នាំ 2013[3]។

កំណើននៃឧស្សាហកម្មនេះ ប្រៀបធៀបក្នុងលក្ខណៈអំណោយផលទល់នឹងការព្យាករណ៍ដែលថាបរិមាណ

---

[1] អង្គការអន្តរជាតិខាងការងារ សូមថ្លែងអំណរគុណក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាវិនិយោគកម្ពុជា និង វិទ្យាស្ថានជាតិស្ថិតិ ចំពោះការជួយគាំទ្រ និង ទិន្នន័យដែលបានប្រើនៅក្នុងព្រឹត្តិបត្រនេះ។ កំហុសទាំងឡាយបើមាន គប្បីត្រូវសន្មតថាជារបស់អង្គការអន្តរជាតិខាងការងារ។

[2] ក្រសួងពាណិជ្ជកម្ម ទិន្នន័យមិនផ្សព្វផ្សាយដែលត្រូវបានផ្តល់ឲ្យអង្គការអន្តរជាតិខាងការងារ។

[3] ក្រសួងពាណិជ្ជកម្ម ទិន្នន័យមិនផ្សព្វផ្សាយដែលត្រូវបានផ្តល់ឲ្យអង្គការអន្តរជាតិខាងការងារ។

នាំចេញអាចនឹងជួលរលំ ដោយសារការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមាថ្មី 100 ដុល្លារ(ចូលជាធរមាននៅថ្ងៃទី 1 ខែកុម្ភៈឆ្នាំ 2014) និង 128 ដុល្លារ(ចាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2015)។ តួលេខកំណើនមានលក្ខណៈកាន់តែគួរឲ្យចាប់អារម្មណ៍ថែមទៀត នៅពេលដែលវិសាលភាពនៃឧស្សាហកម្មនេះត្រូវបានរាប់បញ្ចូល៖ នៅពេលដែលឧស្សាហកម្មមួយរីកកាន់តែធំ និង រីកចំរើនពេញលេញ ការរក្សាអត្រាកំណើនអោយមានលក្ខណៈសមាមាត្រគឺកាន់តែលំបាក ដោយឧស្សាហកម្មនេះបានចាប់ផ្តើមពីមូលដ្ឋានទាបមួយ។

ទិន្នន័យត្រីមាសទីមួយនៃឆ្នាំ 2015 បង្ហាញការចាប់ផ្តើមដ៏រឹងមាំមួយនៃឆ្នាំនេះ។ ការនាំចេញនៃវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង គិតជាទឹកប្រាក់មានចំនួនសរុប 1.5 ពាន់លានដុល្លារ ក្នុងរយៈពេលបីខែដំបូងនៃឆ្នាំ 2015 កើនឡើង 10.6 ភាគរយ ធៀបទៅរយៈពេលដូចគ្នាក្នុងឆ្នាំ 2014 (ការនាំចេញសម្លៀកបំពាក់ បានកើនឡើង 7.9 ភាគរយ ហើយការនាំចេញស្បែកជើង បានកើនឡើង 48.2 ភាគរយ សូមមើលតារាងឧបសម្ព័ន្ធ 1)។

**រូបទី 1. ការនាំចេញសម្លៀកបំពាក់និងស្បែកជើងកម្ពុជា ឆ្នាំ 1995-2015 (លានដុល្លារអាមេរិក)**




ប្រភព: ក្រសួងពាណិជ្ជកម្ម។

**រូបទី 2. ការនាំចេញសម្លៀកបំពាក់និងស្បែកជើងកម្ពុជា គិតតាមគោលដៅធំៗ 1995-2014 (លានដុល្លារសហរដ្ឋអាមេរិក)**




ប្រភព: ក្រសួងពាណិជ្ជកម្ម។

កំណើនជាបន្តនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងត្រូវបាននាំមុខជាពិសេសដោយតម្រូវការខ្លាំងពីអ្នកទិញអឺរ៉ុប។ ក្នុងឆ្នាំ 2014 ការនាំចេញសម្លៀកបំពាក់និងស្បែកជើងទៅកាន់សហភាពអឺរ៉ុប បានកើនឡើងជាង 27 ភាគរយ ខណៈពេលដែលការនាំចេញទៅកាន់សហរដ្ឋអាមេរិក បានថយចុះ 6 ភាគរយ។ ជាលទ្ធផល សហភាពអឺរ៉ុបបានក្លាយជាគោលដៅធំបំផុតតែមួយគត់សម្រាប់ការនាំចេញសម្លៀកបំពាក់និងស្បែកជើងកម្ពុជា ហើយនៅពេលនេះស្រូបយក 42 ភាគរយនៃបរិមាណនាំចេញសរុប។ តួលេខនេះធ្វើអោយសហភាពអឺរ៉ុបនាំមុខសហរដ្ឋអាមេរិក ដែលកាលពីមុនគឺជាទីផ្សារធំជាងគេជាមួយចំណែក 34 ភាគរយ។ ការនាំចេញសម្លៀកបំពាក់និងស្បែកជើងកម្ពុជាចំនួន 24 ភាគរយដែលនៅសល់ក្នុងឆ្នាំ 2014 ត្រូវបានដឹកនាំទៅកាន់ប្រទេសផ្សេងៗទៀតក្នុងពិភពលោក ជាពិសេសកាណាដា និង ជប៉ុន។

វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង គឺ នៅតែជាឧស្សាហកម្មគន្លឹះមួយសម្រាប់ប្រទេសកម្ពុជា។ ការនាំចេញសម្លៀកបំពាក់ និង ស្បែកជើងក្នុងឆ្នាំ 2014 មានចំនួនជិត 79 ភាគរយនៃការនាំចេញទំនិញសរុបរបស់ប្រទេស (ថយចុះពី 90 ភាគរយក្នុងឆ្នាំ 2008)។ វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ក៏ចំណាយមួយចំណែកធំនៃចំណូលលើការនាំចេញលើធាតុចូលអន្តរការី (ដូចជាក្រណាត់ជាដើម)។ យោងតាមធនាគារជាតិនៃកម្ពុជា កានាំទំនិញចូលជាវត្ថុធាតុដើមនៃវិស័យកាត់ដេរសម្លៀក

បំពាក់មានទឹកប្រាក់ចំនួន 2,597 លានដុល្លារក្នុងឆ្នាំ 2014[4] (ធៀបទៅនឹងការនាំចេញសម្លៀកបំពាក់និងស្បែកជើង ដែលមានតម្លៃ 5,817 លានដុល្លារក្នុងឆ្នាំដដែល សូមមើលតារាងឧបសម្ព័ន្ធ I)។

ប្រទេសកម្ពុជាបានចាប់ផ្តើមធ្វើពិពិធកម្មការនាំចេញរបស់ខ្លួន ជាមួយអង្ករ ស្រូវ កៅស៊ូ ត្រី ឈើ និង ផលិតផលឈើ ដែលជាភាគច្រើននៃការនាំចេញក្រៅពីសម្លៀកបំពាក់និងស្បែកជើង។ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជាឆ្នាំ 2015-2025 សំដៅពង្រីកមូលដ្ឋានឧស្សាហកម្មបន្ថែមទៀត ដោយធ្វើពិពិធកម្មនិងបង្កើនការនាំចេញផលិតផលកម្មន្តសាលក្រៅពីសម្លៀកបំពាក់។ គោលដៅនៃគោលនយោបាយនេះ គឺសំដៅកាត់បន្ថយចំណែកនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងមកត្រឹម 50 ភាគរយនៃការនាំចេញទំនិញសរុបមុនដំណាច់ឆ្នាំ 2025។[5] ក្នុងន័យនេះ គោលនយោបាយនេះ សង្កត់ធ្ងន់លើភាពចាំបាច់ត្រូវកែលម្អនិងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មរបស់ប្រទេស។

ប្រការនេះនឹងកាត់បន្ថយហានិភ័យរបស់ប្រទេសចំពោះវិបត្តិនានា ដូចជាការធ្លាក់ចុះនៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងក្នុងឆ្នាំ 2009-10 នៅពេលដែលតម្រូវការនៅក្នុងទីផ្សារនាំចេញសំខាន់ៗរបស់កម្ពុជាបានធ្លាក់ចុះ ដោយសារវិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិភពលោក។ ការថយចុះនៃការនាំចេញ បានធ្វើឲ្យកំណើនសេដ្ឋកិច្ចកម្ពុជាធ្លាក់ចុះ 0.1 ភាគរយក្នុងឆ្នាំ 2009។

## 3. ការវិនិយោគថ្មី ការបើកនិងការបិទរោងចក្រ

**ក – ការវិនិយោគថ្មី:** យោងតាមក្រុមប្រឹក្សាវិនិយោគកម្ពុជា (CIB) គម្រោងវិនិយោគថ្មីចំនួន 78 លើវិស័យកាត់ដេរសម្លៀកបំពាក់និងស្បែកជើង ត្រូវបានអនុម័តក្នុងឆ្នាំ 2014។[6] គម្រោងទាំងនេះ ភាគច្រើនត្រូវបានផ្តល់មូលនិធិដោយវិនិយោគិនពីប្រទេសចិន និង ហុងកុង (ចិន) ជាមួយសមាមាត្រតូចមួយពីតៃវ៉ាន់ (ចិន) និង ប្រទេសផ្សេងៗទៀត។ ការវិនិយោគភាគច្រើនគឺក្នុងទម្រង់ជាឯកកម្មសិទ្ធិ (85 ភាគរយ) និង មានតែប្រហែល 15 ភាគរយប៉ុណ្ណោះដែលមានទម្រង់ជាសហកម្មសិទ្ធិ។ គម្រោងសម្លៀកបំពាក់និងស្បែកជើងថ្មីដែលត្រូវបានអនុម័តក្នុងឆ្នាំ 2014 មានទឹកប្រាក់ចំនួន 452 លានដុល្លារនៃអចលនទ្រព្យ (ថយចុះបន្តិចធៀបទៅនឹងឆ្នាំ 2013 សូមមើលតារាងឧបសម្ព័ន្ធ I)។ ការវិនិយោគនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង តំណាងឲ្យ 28 ភាគរយនៃការវិនិយោគសរុបដែលត្រូវបានអនុម័តនាពេលថ្មីៗ លើតម្លៃអចលនទ្រព្យក្នុងឆ្នាំ 2014។

នៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2015 គម្រោងសម្លៀកបំពាក់និងស្បែកជើងថ្មីចំនួន 19 ថែមទៀត ត្រូវបានអនុម័ត។ តម្លៃសរុបនៃគម្រោងទាំងនេះ មានទឹកប្រាក់ចំនួន 72 លានដុល្លារ ស្មើនឹងពាក់កណ្តាលក្នុងរយៈពេលដូចគ្នានៅក្នុងឆ្នាំមុន – ប៉ុន្តែ ស្មើនឹងជាងពីរដងនៅក្នុងត្រីមាសចុងក្រោយនៃឆ្នាំ 2014។ តួលេខ ច្រើនតែប្រែប្រួលពីត្រីមាសមួយទៅត្រីមាសមួយ ដូច្នេះ តួលេខប្រចាំឆ្នាំផ្តល់ព័ត៌មានបានល្អជាងអំពីនិន្នាការវិនិយោគ។

**ខ – ការបើក ការបិទ និង ការដំណើរការរោងចក្រ:** ខណៈពេលដែលទិន្នន័យអំពីគម្រោងអនុម័តថ្មីៗបង្ហាញថាវិនិយោគិនបរទេសបន្តដាក់ទុនទៅក្នុងរោងចក្រកាត់ដេរ និងស្បែកជើងនៅកម្ពុជា ការបើករោងចក្រថ្មីចាំបាច់ត្រូវពិនិត្យមើលទន្ទឹមគ្នានឹងការបិទរោងចក្រ។ នៅក្នុងសេដ្ឋកិច្ចទីផ្សារមួយ ដែលមានរោងចក្រប្រកួតប្រជែងគ្នា នេះជារឿងធម្មតាមួយដែលថា៖ ក្រុមហ៊ុនដែលមិនសូវចំណេញនឹងត្រូវបិទទ្វារ ខណៈពេលដែលគូប្រកួតប្រជែង និង អ្នកចំណូលថ្មី ដែលមានប្រសិទ្ធភាពជាងឈ្នះចំណែកទីផ្សារ។

យោងតាមតួលេខពីក្រសួងពាណិជ្ជកម្ម ចំនួននៃរោងចក្រកាត់ដេរនិងស្បែកជើងថ្មី បានកើនឡើងពី 528 នៅចុងឆ្នាំ 2013 ដល់ 626 រោងចក្រ នៅចុងឆ្នាំ 2014។ តួលេខនេះគឺជាកំណើនសុទ្ធនៃរោងចក្រចំនួន 98។ តួលេខនេះឆ្លុះបញ្ចាំងការបិទរោងចក្រចំនួន 11 និង ការបើករោងចក្រចំនួន 109 (បើកឡើងវិញក្រោមកម្មសិទ្ធិថ្មី ឬ ក្នុងទម្រង់ជាគម្រោងថ្មី)។

[4] ធនាគារជាតិកម្ពុជាព្រឹត្តិបត្រទិន្នន័យជញ្ជីងទូទាត់ត្រីមាសទី4 ឆ្នាំ2014

[5] គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ឆ្នាំ 2015-2025 (សេចក្តីព្រាង ខែ កុម្ភៈ ឆ្នាំ 2015 ទំព័រ 17)។

[6] ក្នុងចំនួនគម្រោងសរុបនេះ 72 គឺជាគម្រោងកាត់ដេរសម្លៀកបំពាក់ ហើយគម្រោងប្រាំមួយទៀត គឺជាគម្រោងស្បែកជើង។

និន្នាការវិជ្ជមានបានបន្តនៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2015 ដោយការបើករោងចក្រ ជាថ្មីម្តងទៀត មានចំនួន 14 លើសចំនួននៃការបិទរោងចក្រ (រោងចក្រទាំងអស់នេះសុទ្ធតែជារោងចក្រកាត់ដេរ)។ ប្រការនេះធ្វើឲ្យចំនួននៃរោងចក្រកាត់ដេរនិងស្បែកជើងដំណើរការកើនឡើងដល់ 640 នៅដំណាច់ត្រីមាសទីមួយនៃឆ្នាំ 2015 ដែលគឺជាចំនួនខ្ពស់បំផុតនៅក្នុងបញ្ជីនៅក្រសួងពាណិជ្ជកម្ម។ រោងចក្រភាគច្រើនគឺជារោងចក្រកាត់ដេរ (572) រីឯរោងចក្រនៅសល់ផ្សេងទៀត គឺជារោងចក្រស្បែកជើង (68)។

## 4. ការងារនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង

យោងតាមអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ 2012 (CLFS 2012) វិស័យកាត់ដេរសម្លៀកបំពាក់ ស្រូបយក 8.5 ភាគរយនៃការងារទាំងអស់នៅក្នុងប្រទេស។[7] តាំងពីពេលនោះមក ការងារនៅក្នុងវិស័យនេះ បានកើនឡើងថែមទៀត ជាមួយអត្រាមធ្យមនៃការងារថ្មីប្រហែល 60,000 ត្រូវបានបន្ថែមក្នុងមួយឆ្នាំតាំងពីឆ្នាំ 2012 មក។[8] យោងតាមតួលេខដែលកត់ត្រាដោយក្រសួងពាណិជ្ជកម្ម ការងារនៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់និងស្បែកជើង បានកើតឡើងរហូតដល់ឆ្នាំ 2014។ ត្រីមាសនីមួយៗ បានកើនឡើងលើសពីត្រីមាសមុន ដែលកើនឡើងពីកម្មករនិយោជិតចំនួន 539,000 នាក់ (ត្រីមាសទី 1-2014) ដល់ 561,400 នាក់ (ត្រីមាសទី 2-2014), 576,200 នាក់ (ត្រីមាសទី 3-2014) និង ចុងក្រោយដល់ 581,200 នាក់ (ត្រីមាសទី 4-2014)។ ជាមធ្យមកម្មករនិយោជិតប្រមាណ 564,500 នាក់ធ្វើការនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើងក្នុងឆ្នាំ 2014 ធៀបទៅនឹងកម្មករនិយោជិតចំនួន 497,200 នាក់ក្នុងឆ្នាំ 2013 (កំណើនការងារថ្មីសុទ្ធចំនួន 67,300)។ ប្រមាណ 85 ភាគរយនៃការងារបន្ថែមថ្មី ត្រូវបានបង្កើតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ជាមួយការងារ 15 ភាគរយនៅសល់ត្រូវបានបង្កើតដោយវិស័យស្បែកជើង។

ការងារនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង បានបន្តកើនឡើងក្នុងត្រីមាសទីមួយនៃឆ្នាំ 2015។ ក្រសួងពាណិជ្ជកម្ម បានរាប់ឃើញកម្មករនិយោជិតចំនួន 580,900 នាក់ក្នុងខែ មករា ដែលគឺជាចំនួនមួយដែលបានកើនឡើងថែមទៀតដល់ 604,100 នាក់ក្នុងខែ កុម្ភៈ និងកើនឡើងដល់កម្រិតខ្ពស់ឯតទគ្គៈថ្មីមួយទៀតចំនួន 605,100 នាក់ក្នុងខែ មីនា ឆ្នាំ 2015។ ជាមធ្យម កម្មករនិយជិតចំនួន 596,700 នាក់បានធ្វើការនៅក្នុងវិស័យនេះនៅក្នុងត្រីមាសទីមួយនៃឆ្នាំ 2015 ដែលគឺជាកំណើនចំនួន 57,600 នាក់ ធៀបទៅនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ 2014។

## 5. ប្រាក់ឈ្នួល និង តម្លៃ

កំណើនឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ក្នុងទសវត្សរ៍កន្លងទៅ បានជំរុញឲ្យយុវជនកម្ពុជារាប់សែននាក់ធ្វើចំណាកស្រុកទៅកាន់ទីក្រុងដើម្បីរកការងារមានប្រាក់ឈ្នួល។ វឌ្ឍនាការថ្មីៗនៃឧស្សាហកម្មដទៃទៀត រួមជាមួយការធ្វើចំណាកស្រុករបស់កម្មករនិយោជិតទៅរកឱកាសការងារនៅក្រៅប្រទេសកម្ពុជា បានធ្វើឲ្យឧស្សាហកម្មនេះរាយការណ៍អំពីកង្វះកម្លាំងពលកម្ម។ រោងចក្រខ្លះបានផ្តល់ការលើកទឹកចិត្តជាហិរញ្ញវត្ថុបន្ថែមដល់កម្មករនិយោជិតមួយចំនួន ដើម្បីទាក់ទាញកម្លាំងពលកម្ម ខណៈពេលដែលប្រាក់ឈ្នួលជាមូលដ្ឋាននៃកម្មករនិយោជិតចូលធ្វើការថ្មីនៅតែស្របតាមកម្រិតលក្ខន្តិកៈប្រាក់ឈ្នួលអប្បបរមា។

ប្រាក់ឈ្នួលអប្បបរមាកម្ពុជាសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ត្រូវបានដាក់ឲ្យអនុវត្តដំបូងក្នុងឆ្នាំ 1997 ដែលប្រាក់ឈ្នួលអប្បបរមាត្រូវបានកំណត់ក្នុងកម្រិត 40 ដុល្លារក្នុងមួយខែ។ ចាប់តាំងពីពេលនោះមក អត្រានេះបានកើនឡើងដល់ 128 ដុល្លារក្នុងមួយខែ ដែលចូលជាធរមានចាប់ពីថ្ងៃទី 1 ខែ មករា ឆ្នាំ 2015។ ប្រាក់ឈ្នួលអប្បបរមា ត្រូវបានធានាសម្រាប់រាល់កម្មករនិយោជិតធ្វើការពេញម៉ោងនៅក្នុងឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង។ កម្មករនិយោជិតធ្វើការមិនពេញម៉ោង ត្រូវទទួលប្រាក់ឈ្នួលសមាមាត្រទៅនឹងម៉ោងធ្វើការរបស់ពួកគេ។ បន្ថែមលើប្រាក់ឈ្នួលអប្បបរមា ក៏មានប្រាក់ឧបត្ថម្ភផ្សេងៗទៀតផងដែរដែលកម្មករនិយោជិតមានសិទ្ធិទទួល រួមមាន ប្រាក់រង្វាន់ការងារទៀងទាត់ 10 ដុល្លារ, ប្រាក់ឧបត្ថម្ភធ្វើដំណើរ 7 ដុល្លារ និង ប្រាក់ឧបត្ថម្ភអតីតភាពការងាររហូតដល់ 11 ដុល្លារ (ចាប់ពីឆ្នាំទី 11 នៃ

[7] ត្រូវបានផ្តល់និយមន័យថាជា ‘សម្លៀកបំពាក់’។ សូមមើលតារាង 6.10 នៅក្នុងវិទ្យាស្ថានជាតិស្ថិតិ អង្កេតកម្លាំងពលកម្មកម្ពុជា និង អង្កេតពលកម្មកុមារ ឆ្នាំ 2012 (រាជធានីភ្នំពេញ ខែ វិច្ឆិកា ឆ្នាំ 2013)។

[8] ឯកសារក្រសួងពាណិជ្ជកម្ម។ សូមកត់សម្គាល់ថាតួលេខទាំងនេះ គឺរាប់បញ្ចូលតែវិស័យនាំចេញតែប៉ុណ្ណោះ។ បុគ្គលិកការិយាល័យបរទេស និងអ្នកគ្រប់គ្រងបរទេសមិនត្រូវបានរាប់បញ្ចូលក្នុងទិន្នន័យទេ។

ការងារ)។ ទិន្នន័យនេះបង្ហាញថាប្រាក់ឈ្នួលអប្បបរមាមានឥទ្ធិពលលើប្រាក់ឈ្នួលមធ្យម។[9]

**រូបទី 3. ប្រាក់ឈ្នួលអប្បបរមា(តម្លៃបច្ចុប្បន្ន) និង ប្រាក់ឈ្នួលអប្បបរមា(តម្លៃបច្ចុប្បន្ន) បូកថែមអត្ថប្រយោជន៍ផ្សេងៗទៀត នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ឆ្នាំ 2000-2015 (ជាដុល្លារក្នុងមួយខែ)**




ប្រភព: ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវ:

ដូចត្រូវបានបង្ហាញជូនក្នុងក្រាហ្វិក (រូបទី 4) បន្ទាប់ប្រាក់ឈ្នួលមធ្យមបាននៅទ្រឹងចាប់ពីពាក់កណ្តាលឆ្នាំ 2000 ដល់ពាក់កណ្តាលឆ្នាំ 2006 ដែលគឺជារយៈពេលមួយ ដែលនៅក្នុងនោះ ប្រាក់ឈ្នួលអប្បបរមា (តម្លៃបច្ចុប្បន្ន) គ្មានការប្រែប្រួលក្នុងកម្រិត 45 ដុល្លារក្នុងមួយខែ។ យោងតាមការគណនាដោយផ្អែកលើទិន្នន័យពីក្រសួងពាណិជ្ជកម្ម ប្រាក់ឈ្នួលមធ្យមប្រចាំខែរបស់កម្មករនិយោជិតកាត់ដេរក្នុងអំឡុងពេលនេះគឺមានកម្រិតត្រឹមតែ 66 ដុល្លារប៉ុណ្ណោះ។ ជាមួយការដំឡើងប្រាក់ឈ្នួលអប្បបរមាក្រោយពេលនោះ ប្រាក់ឈ្នួលមធ្យមបានចាប់ផ្តើមកើនឡើង។ នៅពេលដែលប្រាក់ឈ្នួលអប្បបរមាត្រូវបានដំឡើងនៅចុងឆ្នាំ 2006 ដល់ 50 ដុល្លារ ប្រាក់ឈ្នួលមធ្យមប្រចាំខែដែលទទួលបានដោយកម្មករនិយោជិតកាត់ដេរបានកើនឡើងដល់ 73 ដុល្លារ (ខែ ធ្នូ ឆ្នាំ 2006) និង បន្ទាប់មក បានកើនឡើងដល់ 146 ដុល្លារ ក្នុង ខែ ធ្នូ ឆ្នាំ 2014 នៅពេលដែលប្រាក់ឈ្នួលអប្បបរមា ស្ថិតក្នុងកម្រិត 100 ដុល្លារ។

**រូបទី 4. ប្រាក់ឈ្នួលអប្បបរមា ប្រចាំខែ (តម្លៃបច្ចុប្បន្ន) និង ប្រាក់ឈ្នួលជាមធ្យម ប្រចាំខែ (តម្លៃបច្ចុប្បន្ន) នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ឆ្នាំ 2000-2015 (ជាដុល្លារក្នុងមួយខែ)**




ប្រភព: ក្រសួងពាណិជ្ជកម្ម។

ប៉ុន្តែ កំណើននៅក្នុងប្រាក់ឈ្នួល(តម្លៃបច្ចុប្បន្ន) បំផ្លើសកម្រៃពិតដែលទទួលបានដោយកម្មករនិយោជិត ក្រោយពេលរាប់បញ្ចូលអតិផរណា។ ដើម្បីកែតម្រូវតាមឥទ្ធិពលនេះ រូបទី 5 បង្ហាញទាំងប្រាក់ឈ្នួលមធ្យម(តម្លៃបច្ចុប្បន្ន) ទាំងប្រាក់ឈ្នួលមធ្យមពិត។ ប្រាក់ឈ្នួលពិតរាប់បញ្ចូលអត្រាអតិផរណានៃតម្លៃទំនិញប្រើប្រាស់របស់ប្រទេស និងដោយហេតុនេះ បង្ហាញនិន្នាការនៅក្នុងអំណាចទិញរបស់កម្មករនិយោជិត។ ឆ្នាំមូលដ្ឋានដែលត្រូវបានប្រើគឺខែ ធ្នូ ឆ្នាំ 2010។

ទិដ្ឋភាពសំខាន់បំផុតនៃរូបទី 5 គឺបង្ហាញនិន្នាការពីពេលមួយទៅពេលមួយ មិនមែនបង្ហាញពីកម្រិតនៃប្រាក់ឈ្នួលជាដុល្លារអាមេរិកតម្លៃបេរនោះទេ ព្រោះថាកម្រិតប្រាក់ឈ្នួលនឹងប្រែប្រួលប្រសិនបើឆ្នាំមូលដ្ឋានផ្សេងទៀតត្រូវបានប្រើ។ របកគំហើញសំខាន់ គឺថាអំណាចទិញរបស់កម្មករនិយោជិតបានថយចុះក្នុងចន្លោះឆ្នាំ 2003 និង 2009។

[9] សូមកត់សម្គាល់ថាតួលេខប្រាក់ឈ្នួលជាមធ្យមដែលត្រូវបានបង្ហាញក្នុងព្រឹត្តិបត្រនេះ រួមមានប្រាក់ឧបត្ថម្ភផ្សេងៗ និង ប្រាក់ធ្វើការបន្ថែមម៉ោង។

ប្រាក់ចំណូលពិតមធ្យមរបស់កម្មករនិយោជិតកាត់ដេរ បានធ្លាក់ចុះពី 111 ដុល្លារ ក្នុងឆ្នាំ 2003 មកត្រឹម 88 ដុល្លារ មុនដំណាច់ឆ្នាំ 2009 (គិតជាតម្លៃថេរ ខែ ធ្នូ ឆ្នាំ 2010)។ ចំណុចនេះ ត្រូវបានបណ្តាលដោយកត្តាពីរ។ ទីមួយ ដោសារកំណើនយឺត និង នៅក្នុងឆ្នាំខ្លះ ការស្ថិតនៅទ្រឹង នៃប្រាក់ឈ្នួល(តម្លៃបច្ចុប្បន្ន) ដោយសារកង្វះការកែសម្រួលប្រាក់ឈ្នួលអប្បបរមា។ ទីពីរ អត្រាអតិផរណាមានកម្រិតខ្ពស់ជាមធ្យម 7.1 ភាគរយក្នុងមួយឆ្នាំក្នុងអំឡុងពេលពីឆ្នាំ 2003 ដល់ឆ្នាំ 2009។ ជាលទ្ធផល កម្មករនិយោជិតអាចទិញបានតិចជាងជាមួយប្រាក់ឈ្នួលដែលពួកគេបានទទួល។

កម្មករនិយោជិតកម្ពុជា បានទទួលប្រយោជន៍ពីអតិផរណាទាបនៃតម្លៃទំនិញប្រើប្រាស់ក្នុងបណ្តាឆ្នាំថ្មីៗនេះ ដែលមានកម្រិតជាមធ្យម 3.8 ភាគរយ ក្នុងមួយឆ្នាំ ពីឆ្នាំ 2010 ដល់ឆ្នាំ 2014។ គួបផ្សំជាមួយកំណើនខ្លាំងនៅក្នុងប្រាក់ឈ្នួល(តម្លៃបច្ចុប្បន្ន) ប្រការនេះបាននាំទៅដល់ការស្រង់បានមកវិញនៅការបាត់បង់កន្លងមកនៅក្នុងអំណាចទិញ និង កំណើនខ្លះ។ ប្រាក់ឈ្នួលពិតមធ្យមប្រចាំខែរបស់កម្មករនិយោជិតកាត់ដេរ បានកើនឡើងពី 93 ដុល្លារ ក្នុងឆ្នាំ 2010 ដល់ 126 ដុល្លារ ក្នុងឆ្នាំ 2014 (គិតជាតម្លៃថេរ ខែ ធ្នូ ឆ្នាំ 2010)។ តួលេខនេះ ស្មើនឹងកំណើនមធ្យម 8 ភាគរយក្នុងមួយឆ្នាំ (ក្នុងអំឡុងពេលពីឆ្នាំ 2010-2014) ក្រោយកែសម្រួលតាមអតិផរណា។

ទិន្នន័យពីក្រសួងពាណិជ្ជកម្មសម្រាប់ត្រីមាសទីមួយនៃឆ្នាំ 2015 បង្ហាញថាកម្មករនិយោជិតកាត់ដេរ បានទទួលផលថែមទៀតពីប្រាក់ឈ្នួលអប្បបរមាថ្មីចំនួន 128 ដុល្លារ ដែលចូលជាធរមាននៅថ្ងៃទី 1 ខែ មករា 2015។ ប្រាក់ឈ្នួលមធ្យម(តម្លៃបច្ចុប្បន្ន) របស់កម្មករនិយោជិតកាត់ដេរ (ដែលរួមទាំងការធ្វើការបន្ថែមម៉ោង និង ប្រាក់រង្វាន់) បានកើនឡើងពី 139 ដុល្លារក្នុងត្រីមាសទីមួយនៃឆ្នាំ 2014 ដល់ 165 ដុល្លារក្នុងត្រីមាសទី 1 នៃ ឆ្នាំ 2015 ដែលគឺជាកំណើនប្រហែល 18.9 ភាគរយ។[10] នៅពេលដែលឥទ្ធិពលនៃអតិផរណាត្រូវបានរាប់បញ្ចូល ដោយការបំប្លែងតួលេខទាំងនេះទៅជាតម្លៃខែ ធ្នូ ឆ្នាំ 2010 ប្រាក់ឈ្នួលមធ្យមពិតរបស់កម្មករនិយោជិតកាត់ដេរបានកើនឡើងពី 123 ដុល្លារ ក្នុងត្រីមាសទី 1 ឆ្នាំ 2014 ដល់ 144 ដុល្លារ ដុល្លារ ក្នុងត្រីមាសទី 1 ឆ្នាំ 2015 (កំណើន 17.7 ភាគរយគិតជាអត្រាពិត)។[11]

**រូបទី 5. ប្រាក់ឈ្នួល(តម្លៃបច្ចុប្បន្ន) និងតម្លៃមធ្យមពិតប្រចាំខែ ក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ឆ្នាំ 2002-2015 (ជាដុល្លារក្នុងមួយខែ)**




ប្រភព: វិទ្យាស្ថានជាតិស្ថិតិ (អតិផរណា) ក្រសួងពាណិជ្ជកម្ម (ប្រាក់ឈ្នួល និង កម្មករនិយោជិត) និង ការគណនារបស់បុគ្គលិកនៃអង្គការអន្តរជាតិខាងការងារ។

### 6. កិច្ចដំណើរការនៃគណៈកម្មាធិការប្រឹក្សាការងារ ដើម្បីកែសម្រួលប្រាក់ឈ្នួលអប្បបរមានៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង

ក្រោមកិច្ចព្រមព្រៀងមួយដែលត្រូវបានសម្រេចដោយតំណាងរាជរដ្ឋាភិបាល សហជីព និង និយោជកកាលពីខែ មិថុនា ឆ្នាំ 2014 គណៈកម្មាធិការប្រឹក្សាការងារ (LAC) នឹងពិនិត្យមើលប្រាក់ឈ្នួលអប្បបរមាឡើងវិញរៀងរាល់ឆ្នាំ។ កិច្ចដំណើរការនេះ ត្រូវបានគ្រោងចាប់ផ្តើមក្នុងត្រីមាសទីបីនៃឆ្នាំនីមួយៗ ជាមួយប្រកាសថ្មីមួយចូលជាធរមាននៅថ្ងៃទី 1 ខែ មករា នៃឆ្នាំបន្ទាប់។[12] ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈក្នុងតួនាទីជាអគ្គលេខាធិការដ្ឋាននៃ LAC ត្រូវបានរំពឹងថានឹងបន្តតួនាទីរបស់ខ្លួនក្នុងការជួយសម្រួល និង សម្របសម្រួលកិច្ចដំណើរការនេះ ដែលពាក់ព័ន្ធការ

[10] ដោយសាររបៀបដែលប្រព័ន្ធមូលដ្ឋានទិន្នន័យរបស់ក្រសួងត្រូវបានធ្វើបច្ចុប្បន្នកម្ម កំណើននៅក្នុងប្រាក់ឈ្នួលអាចត្រូវបានបង្ហាញជាមួយគម្លាតពេលវេលាដ៏ខ្លីមួយនៅក្នុងតួលេខ។

[11] សូមកត់សម្គាល់(តម្លៃបច្ចុប្បន្ន) ថាតួលេខភាគរយកំណើន គឺផ្អែកលើកម្រិតប្រាក់ឈ្នួលពិតដល់កម្រិតទសភាគ។

[12] សូមមើលសេចក្តីប្រកាសរបស់គណៈកម្មាធិការប្រឹក្សាការងារ (ចុះថ្ងៃទី 16 ខែ មិថុនា ឆ្នាំ 2014)។

សន្ទនាត្រីភាគី ដែលរួមមានតំណាងមកពីសហជីព និយោជក និង រាជរដ្ឋាភិបាលខ្លួនឯង។ អង្គការអន្តរជាតិខាងការងារ បន្តផ្តល់ការជួយគាំទ្រផ្នែកបច្ចេកទេសជូនលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រឹក្សាការងារ ក្នុងការពិភាក្សាអំពីប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង។

ការពិនិត្យមើលប្រាក់ឈ្នួលអប្បបរមាឡើងវិញ គឺផ្អែកលើមាត្រា 107 នៃច្បាប់ការងារកម្ពុជា ដែលផ្តល់ជូនគណៈកម្មាធិការប្រឹក្សាការងារនូវអំណាចផ្តល់អនុសាសន៍អំពីកម្រិតប្រាក់ឈ្នួលអប្បបរមាជូនក្រសួងទទួលបន្ទុកលើការងារ។ ច្បាប់នេះចែងថា "ប្រាក់ឈ្នួល [អប្បបរមា] នេះត្រូវកែសម្រួលទៅតាមដំណាក់កាលនៃការវិវត្តស្ថានភាពសេដ្ឋកិច្ច និងតម្លៃជីវភាពរស់នៅ"។ ច្បាប់នេះ ក៏ចែងផងដែរ ថាការកែសម្រួល តាមដែលអាចធ្វើទៅបាន គប្បីត្រូវគិតគូរដល់លក្ខណៈវិនិច្ឆ័យផ្នែកសង្គម ដូចជាសេចក្តីត្រូវការរបស់កម្មករនិយោជិត និង គ្រួសារពួកគេ និង ការវិវត្តនៃតម្លៃជីវភាពរស់នៅ (ឬ អតិផរណា) និង ទន្ទឹមគ្នានេះក៏ត្រូវយកចិត្តទុកដាក់ផងដែរលើកត្តាសេដ្ឋកិច្ចនានា។ ការពិគ្រោះយោបល់ដែលត្រូវបានធ្វើនៅដើមឆ្នាំ 2014 បានគូសបង្ហាញភាពចាំបាច់ត្រូវធ្វើការសិក្សាផលប៉ះពាល់នៃប្រាក់ឈ្នួលអប្បបរមាលើសហគ្រាស លើភាពប្រកួតប្រជែងនៃប្រទេសកម្ពុជា និង លើទីផ្សារការងារ និង មុខរបរ។

**រូបទី 6. ប្រាក់ឈ្នួលអប្បបរមាប្រចាំខែ និង ការងារ នៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង ឆ្នាំ 2000-2015 (ជាដុល្លារ និង ចំនួនកម្មករនិយោជិត)**




ប្រភព: ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ (ប្រាក់ឈ្នួលអប្បបរមា) និង ក្រសួងពាណិជ្ជកម្ម (ចំនួនកម្មករនិយោជិត)។ សូមកត់សម្គាល់ថាតួលេខកម្មករនិយោជិតសំដៅតែលើវិស័យនាំចេញប៉ុណ្ណោះ។

ទិន្នន័យក្នុងព្រឹត្តិបត្រនេះ បង្ហាញថាកំណើនការងាររឹងមាំ បានបន្តពេញឆ្នាំ 2014 និង ចូលដល់ 2015 (សូមមើល រូបទី 6)។ ប៉ុន្តែ ប្រាក់ឈ្នួលអប្បបរមាកម្ពុជា បានចាប់ផ្តើមចេញពីមូលដ្ឋានដ៏ទាបមួយមុនពេលដំឡើងជាបន្តបន្ទាប់ក្នុងរយៈពេលប្រាំឆ្នាំកន្លងមកនេះ។ កម្រិត 128 ដុល្លារបច្ចុប្បន្ននេះ នៅតែមានកម្រិតទាបជាង ប្រទេសប្រកួតប្រជែងនានា ដូចជាប្រទេសចិន ហ្វីលីពីន និង ថៃ (ដែលប្រទេសទាំងអស់នេះ សុទ្ធតែមានអត្រាផលិតភាពការងារខ្ពស់ជាងកម្ពុជា)[13]។ ផ្ទុយទៅវិញ ប្រាក់ឈ្នួលអប្បបរមាកម្ពុជា នៅពេលនេះ គឺខ្ពស់ជាងកម្រិតនៅប្រទេសស្រីលង្កា (66 ដុល្លារ) បង់ក្លាដេស (71 ដុល្លារ) និង ប៉ាគីស្ថាន (ពី 99 ដុល្លារ ដល់ 119 ដុល្លារ)។

[13] សូមមើលអង្គការអន្តរជាតិខាងការងារ (2015) World Employment and Social Outlook. Geneva។

**រូបទី 7. ប្រាក់ឈ្នួលអប្បបរមាប្រចាំខែ ដែលអនុវត្តលើវិស័យកាត់ដេរសម្លៀកបំពាក់នៅក្នុងប្រទេសអាស៊ីនាំចេញសម្លៀកបំពាក់ធំៗ គិតត្រឹមថ្ងៃទី 1 ខែ មករា ឆ្នាំ 2015 (ជាដុល្លារ)**




* ចូលជាធរមាននៅថ្ងៃទី 1 ខែ មករា ឆ្នាំ 2015។

កំណត់សម្គាល់: អត្រាទាំងអស់ គឺសំដៅលើកម្រិតជំនាញទាបបំផុត និង អ្នកចូលធ្វើការថ្មី។ សម្រាប់បណ្តាប្រទេសដែលមានប្រព័ន្ធប្រាក់ឈ្នួលអប្បបរមាបែបវិមជ្ឈការ (ចិន ឥណ្ឌា ឥណ្ឌូណេស៊ី ប៉ាគីស្ថង់ និង ហ្វីលីពីន) ទស្សនៈរូមនេះឆ្លុះបញ្ចាំងអត្រានានានៅប្រទេសផលិតសម្លៀកបំពាក់សំខាន់ៗ។

ប្រភព: ការចងក្រងដោយអង្គការអន្តរជាតិខាងការងារ ដោយផ្អែកលើឯកសារផ្លូវការ។

## 7. សេក្តីសង្ខេប

វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង បានបន្តដំណើរការយ៉ាងរឹងមាំក្នុងឆ្នាំ 2014 និង ត្រីមាសទីមួយនៃឆ្នាំ 2015។ ការនាំចេញបានបន្តកើនឡើង ទន្ទឹមគ្នានឹងការងារ និង ប្រាក់ឈ្នួលមធ្យមរបស់កម្មករនិយោជិត។ មានកំណើនសុទ្ធនៅក្នុងចំនួនរោងចក្រកំពុងដំណើរការ។ ការនាំចេញនៃវិស័យនេះទៅកាន់សហភាពអឺរ៉ុប បន្តកើនឡើងជាចំណែកមួយនៃការនាំចេញសរុប។ ប្រាក់ឈ្នួលអប្បបរមាដែលកើនដល់ 128 ដុល្លារ ដែលចូលជាធរមានតាំងពីខែ មករា ឆ្នាំ 2015 បានកើតឡើងទន្ទឹមគ្នានឹងកំណើនការងារជាបន្តដ៏រឹងមាំ។

ទិន្នន័យនិងការវិភាគទាំងនេះត្រូវបានរំពឹងថា នឹងចូលរូមជាព័ត៌មានក្នុងការពិភាក្សាអំពីស្ថានភាពបច្ចុប្បន្ន និង អនាគត នៃវិស័យកាត់ដេរនិងស្បែកជើងរបស់កម្ពុជា រួមទាំងការពិភាក្សាអំពីកម្រិតប្រាក់ឈ្នួល និង ការកំណត់ប្រាក់ឈ្នួលអប្បបរមាផងដែរ។

## តារាងឧបសម្ព័ន្ធ 1. ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើងកម្ពុជា – សូចនាករជម្រើស

| | 2013 | | | | | 2014 | | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2013 | Q1 | Q2 | Q3 | Q4 | 2014 | Jan | Feb | Mar | Q1 |
| **1. ទិន្នផលសេដ្ឋកិច្ច (លានដុល្លារ )** | | | | | | | | | | | | | | |
| **ផ.ស.ស. (% កំណើនពិត)** | - | - | - | - | 7.4 | - | - | - | - | 7.0 | - | - | - | - |
| **ផ.ស.ស. (% កំណើនតាមតម្លៃបច្ចុប្បន្ន)** | - | - | - | - | 8.2 | - | - | - | - | 10.0 | - | - | - | - |
| **ផ.ស.ស. (តម្លៃបច្ចុប្បន្ន)** | - | - | - | - | 15,228 | - | - | - | - | 16,709 | - | - | - | - |
| តម្លៃបន្ថែម (សម្លៀកបំពាក់ និងស្បែកជើង, តម្លៃបច្ចុប្បន្ន) | - | - | - | - | 1,560 | - | - | - | - | 1,790 | - | - | - | - |
| តម្លៃបន្ថែម (សម្លៀកបំពាក់ និងស្បែកជើង គិតជា % នៃ ផ.ស.ស.) | | | | | 10.2 | | | | | 10.7 | | | | |
| **2. ការនាំចេញសម្លៀកបំពាក់និងស្បែកជើង** | | | | | | | | | | | | | | |
| ***2ក. កំណើននៃការនាំចេញសម្លៀកបំពាក់និងស្បែកជើងសរុប*** | | | | | | | | | | | | | | |
| **ការនាំចេញសម្លៀកបំពាក់ និង ស្បែកជើង (ជាលានដុល្លារ ) 1/** | **1,159** | **1,231** | **1,597** | **1,334** | **5,320** | **1,341** | **1,321** | **1,684** | **1,470** | **5,817** | **458** | **517** | **508** | **1,484** |
| % កំណើន (ធៀបនឹងឆ្នាំមុន) | 8.7 | 18.9 | 11.2 | 9.3 | 11.8 | 15.7 | 7.3 | 5.5 | 10.2 | 9.3 | 45.6 | 5.6 | -5.3 | 10.6 |
| ការនាំចេញសម្លៀកបំពាក់1/ | 1,077 | 1,142 | 1,502 | 1,246 | 4,967 | 1,249 | 1,221 | 1,566 | 1,343 | 5,379 | 414 | 469 | 464 | 1,347 |
| % កំណើន (ធៀបនឹងឆ្នាំមុន) | 7.3 | 19.2 | 11.0 | 10.2 | 11.7 | 16.0 | 6.9 | 4.3 | 7.8 | 8.3 | 40.5 | 3.4 | -7.3 | 7.9 |
| ការនាំចេញស្បែកជើង | 82 | 89 | 95 | 87 | 354 | 92 | 100 | 119 | 127 | 438 | 45 | 48 | 44 | 137 |
| % កំណើន (ធៀបនឹងឆ្នាំមុន) | 32.0 | 15.6 | 15.6 | -2.6 | 13.6 | 12.0 | 13.2 | 24.6 | 45.1 | 23.9 | 119.8 | 32.1 | 23.8 | 48.2 |
| **ការនាំទំនិញចូលប្រើប្រាស់ក្នុងស្រុកនៃសម្ភារកាត់ដេរ** | **-546** | **-637** | **-692** | **-616** | **-2,490** | **-586** | **-681** | **-651** | **-678** | **-2,597** | - | - | - | - |
| ***2ខ. ការនាំចេញសម្លៀកបំពាក់និងស្បែកជើង តាមគោលដៅសំខាន់ៗ*** | | | | | | | | | | | | | | |
| **ការនាំចេញសរុប (សម្លៀកបំពាក់ និង ស្បែកជើងជាលានដុល្លារ)** | **1,159** | **1,231** | **1,597** | **1,334** | **5,320** | **1,341** | **1,321** | **1,684** | **1,470** | **5,817** | **458** | **517** | **508** | **1,484** |
| ទៅកាន់សហរដ្ឋអាមេរិក (សម្លៀកបំពាក់និងស្បែកជើង)1/ | 530 | 481 | 590 | 467 | 2,068 | 516 | 453 | 529 | 446 | 1,944 | 168 | 154 | 153 | 475 |
| ទៅកាន់សហភាពអឺរ៉ុប (សម្លៀកបំពាក់និងស្បែកជើង)1/ | 360 | 435 | 593 | 540 | 1,929 | 440 | 513 | 786 | 718 | 2,458 | 177 | 232 | 214 | 623 |
| ទៅកាន់ប្រទេសផ្សេងៗទៀត (សម្លៀកបំពាក់និងស្បែកជើង)1/ | 269 | 315 | 413 | 326 | 1,324 | 385 | 355 | 370 | 306 | 1,415 | 114 | 131 | 141 | 386 |
| **ការនាំចេញសម្លៀកបំពាក់សរុប (ជាលានដុល្លារ)1/** | **1,077** | **1,142** | **1,502** | **1,246** | **4,967** | **1,249** | **1,221** | **1,566** | **1,343** | **5,379** | **414** | **469** | **464** | **1,347** |
| ទៅកាន់សហរដ្ឋអាមេរិក សម្លៀកបំពាក់1/ | 519 | 471 | 578 | 458 | 2,026 | 497 | 435 | 514 | 426 | 1,872 | 157 | 144 | 145 | 447 |
| ទៅកាន់សហភាពអឺរ៉ុប សម្លៀកបំពាក់1/ | 324 | 390 | 550 | 493 | 1,757 | 403 | 462 | 720 | 650 | 2,236 | 156 | 209 | 192 | 557 |
| ទៅកាន់ប្រទេសផ្សេងៗទៀត សម្លៀកបំពាក់1/ | 234 | 281 | 374 | 294 | 1,184 | 349 | 323 | 331 | 268 | 1,271 | 101 | 116 | 127 | 343 |

| | 2013 | | | | | 2014 | | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2013 | Q1 | Q2 | Q3 | Q4 | 2014 | Jan | Feb | Mar | Q1 |
| **ការនាំចេញ ស្បែកជើង សរុប (ជាលានដុល្លារ)** | **82** | **89** | **95** | **87** | **354** | **92** | **100** | **119** | **127** | **438** | **45** | **48** | **44** | **137** |
| ទៅកាន់សហរដ្ឋអាមេរិក (ស្បែកជើង) | 11 | 10 | 13 | 8 | 42 | 19 | 17 | 15 | 20 | 72 | 10 | 10 | 8 | 28 |
| ទៅកាន់សហភាពអឺរ៉ុប (ស្បែកជើង) | 36 | 45 | 43 | 47 | 172 | 37 | 51 | 65 | 69 | 222 | 21 | 22 | 23 | 66 |
| ទៅកាន់ប្រទេសផ្សេងៗទៀត (ស្បែកជើង) | 35 | 34 | 39 | 32 | 140 | 36 | 32 | 38 | 38 | 144 | 13 | 16 | 14 | 43 |
| **3. ការវិនិយោគថ្មី ការបើករោងចក្រ និង ការបិទរោងចក្រ** | | | | | | | | | | | | | | |
| ***3ក. គម្រោងវិនិយោគថ្មី*** | | | | | | | | | | | | | | |
| **គម្រោងវិនិយោគសរុបដែលអនុម័តដោយក្រុមប្រឹក្សាវិនិយោគ** | **41** | **32** | **34** | **53** | **160** | **44** | **48** | **42** | **15** | **149** | **10** | **5** | **22** | **37** |
| ***ក្នុងនោះ:*** **គម្រោងសម្លៀកបំពាក់ និង ស្បែកជើង** | **29** | **17** | **19** | **24** | **89** | **25** | **32** | **15** | **6** | **78** | **3** | **5** | **11** | **19** |
| គម្រោងកាត់ដេរ | 25 | 15 | 14 | 21 | 75 | 24 | 29 | 13 | 6 | 72 | 2 | 5 | 10 | 17 |
| គម្រោងស្បែកជើង | 4 | 2 | 5 | 3 | 14 | 1 | 3 | 2 | 0 | 6 | 1 | 0 | 1 | 2 |
| **គម្រោងសរុបដែលអនុម័តដោយក្រុមប្រឹក្សាវិនិយោគ (ជាលានដុល្លារ)** | **212** | **2,128** | **260** | **1,882** | **4,483** | **446** | **382** | **626** | **150** | **1,604** | **62** | **16** | **2,795** | **2,873** |
| ***ក្នុងនោះ:*** **គម្រោងសម្លៀកបំពាក់ និង ស្បែកជើង (ជាលានដុល្លារ)** | **138** | **118** | **90** | **118** | **463** | **135** | **200** | **86** | **30** | **452** | **16** | **16** | **39** | **72** |
| គម្រោងកាត់ដេរ (ជាដុល្លារ) | 103 | 103 | 67 | 100 | 374 | 127 | 174 | 77 | 30 | 408 | 11 | 16 | 37 | 64 |
| គម្រោងស្បែកជើង (ជាដុល្លារ) | 35 | 15 | 22 | 18 | 90 | 7 | 27 | 9 | 0 | 44 | 5 | 0 | 2 | 8 |
| ***3ខ. ការបើករោងចក្រ និង ការបិទរោងចក្រ*** | | | | | | | | | | | | | | |
| **ចំនួនរោងចក្រកាត់ដេរ និង ស្បែកជើងសរុប (ចុងគ្រា)** | **456** | **487** | **513** | **528** | **528** | **548** | **576** | **597** | **626** | **626** | **631** | **634** | **640** | **640** |
| រោងចក្រកាត់ដេរ (ចុងគ្រា) | 405 | 434 | 458 | 469 | 469 | 488 | 515 | 532 | 558 | 558 | 563 | 566 | 572 | 572 |
| រោងចក្រស្បែកជើង (ចុងគ្រា) | 51 | 53 | 55 | 59 | 59 | 60 | 61 | 65 | 68 | 68 | 68 | 68 | 68 | 68 |
| **បើកសុទ្ធសរុប (សម្លៀកបំពាក់ និង ស្បែកជើង)** | **17** | **31** | **26** | **15** | **89** | **20** | **28** | **21** | **29** | **98** | **5** | **3** | **6** | **14** |
| រោងចក្រកាត់ដេរ | 14 | 29 | 24 | 11 | 78 | 19 | 27 | 17 | 26 | 89 | 5 | 3 | 6 | 14 |
| រោងចក្រស្បែកជើង | 3 | 2 | 2 | 4 | 11 | 1 | 1 | 4 | 3 | 9 | 0 | 0 | 0 | 0 |
| **បើក (សម្លៀកបំពាក់ និង ស្បែកជើង)** | **22** | **33** | **28** | **18** | **101** | **23** | **32** | **25** | **29** | **109** | **5** | **3** | **6** | **14** |
| រោងចក្រកាត់ដេរ | 18 | 31 | 26 | 14 | 89 | 21 | 30 | 21 | 26 | 98 | 5 | 3 | 6 | 14 |
| រោងចក្រស្បែកជើង | 4 | 2 | 2 | 4 | 12 | 2 | 2 | 4 | 3 | 11 | 0 | 0 | 0 | 0 |
| **បិទ (សម្លៀកបំពាក់ និង ស្បែកជើង)** | **5** | **2** | **2** | **3** | **12** | **3** | **4** | **4** | **0** | **11** | **0** | **0** | **0** | **0** |
| រោងចក្រកាត់ដេរ | 4 | 2 | 2 | 3 | 11 | 2 | 3 | 4 | 0 | 9 | 0 | 0 | 0 | 0 |
| រោងចក្រស្បែកជើង | 1 | 0 | 0 | 0 | 1 | 1 | 1 | 0 | 0 | 2 | 0 | 0 | 0 | 0 |
| **4. ការងារនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង** | | | | | | | | | | | | | | |

| | 2013 | | | | | 2014 | | | | | 2015 | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | Q1 | Q2 | Q3 | Q4 | 2013 | Q1 | Q2 | Q3 | Q4 | 2014 | Jan | Feb | Mar | Q1 |
| **កម្មករនិយោជិតកាត់ដេរ និង ស្បែកជើងសរុប (មធ្យមនៃពេល, '000)** | **458** | **482** | **516** | **533** | **497** | **539** | **561** | **576** | **581** | **564** | **581** | **604** | **605** | **597** |
| % change (ធៀបនឹងឆ្នាំមុន) | 15.2 | 18.8 | 20.1 | 20.1 | 18.6 | 17.6 | 16.5 | 11.7 | 9.1 | 13.5 | 9.5 | 12.2 | 10.4 | 10.7 |
| កម្មករនិយោជិតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ (មធ្យមនៃពេល, '000) | 386 | 404 | 434 | 447 | 418 | 454 | 475 | 484 | 488 | 475 | 488 | 505 | 507 | 500 |
| កម្មករនិយោជិតនៅក្នុងវិស័យស្បែកជើង (មធ្យមនៃពេល, '000) | 72 | 78 | 82 | 86 | 80 | 85 | 87 | 92 | 93 | 89 | 93 | 99 | 98 | 97 |
| **5. ប្រាក់ឈ្នួល និង តម្លៃ** | | | | | | | | | | | | | | |
| **ប្រាក់ឈ្នួលអប្បបរមា (វិស័យកាត់ដេរសម្លៀកបំពាក់ និង ស្បែកជើង, US$)** | **61** | **80**[2/] | **80** | **80** | **80** | **100**[3/] | **100** | **100** | **100** | **100** | **128** | **128** | **128** | **128** |
| **ប្រាក់ឈ្នួលមធ្យមប្រចាំខែ (កាត់ដេរសម្លៀកបំពាក់និង ស្បែកជើង, US$)**[4/] | **119** | **121** | **127** | **128** | **124** | **137** | **145** | **152** | **146** | **145** | **149** | **170** | **171** | **164** |
| ប្រាក់ឈ្នួលមធ្យមប្រចាំខែ (កម្មករនិយោជិតកាត់ដេរ)[4/] | 121 | 123 | 129 | 129 | 126 | 139 | 147 | 153 | 146 | 146 | 151 | 171 | 172 | 165 |
| ប្រាក់ឈ្នួលមធ្យមប្រចាំខែ (កម្មករនិយោជិតស្បែកជើង)[4/] | 109 | 110 | 117 | 120 | 114 | 127 | 137 | 149 | 146 | 140 | 143 | 161 | 165 | 157 |
| **ប្រាក់ឈ្នួលពិតមធ្យមប្រចាំខែ (សម្លៀកបំពាក់និងស្បែកជើង)4/ 5/** | **110** | **111** | **114** | **114** | **113** | **121** | **127** | **131** | **127** | **127** | **132** | **148** | **149** | **143** |
| ប្រាក់ឈ្នួលពិតមធ្យមប្រចាំខែ (សម្លៀកបំពាក់)[4/ 5/] | 112 | 113 | 116 | 115 | 114 | 123 | 128 | 132 | 127 | 128 | 133 | 150 | 150 | 144 |
| ប្រាក់ឈ្នួលពិតមធ្យមប្រចាំខែ (ស្បែកជើង)[4/ 5/] | 101 | 101 | 105 | 107 | 104 | 113 | 119 | 129 | 127 | 122 | 126 | 140 | 144 | 137 |
| **សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់ (មធ្យមនៃពេល) គណនាឆ្នាំមូលដ្ឋានឡើងវិញ ខែ ធ្នូ ឆ្នាំ 2010=100** | **108.1** | **109.3** | **111.4** | **112.3** | **110.2** | **113.0** | **114.5** | **115.8** | **114.7** | **114.5** | **113.3** | **114.6** | **114.7** | **114.2** |
| **អត្រាអតិផរណា (មធ្យមនៃពេល, កំណើនធៀបនឹងឆ្នាំមុន)** | **1.5%** | **2.3%** | **3.7%** | **4.3%** | **2.9%** | **4.6%** | **4.8%** | **4.0%** | **2.1%** | **3.9%** | **0.4%** | **1.6%** | **1.1%** | **1.0%** |

1/ រាប់បញ្ចូលវាយនភណ្ឌ។

2/ ចូលជាធរមាន ថ្ងៃទី 1 ខែ ឧសភា ឆ្នាំ 2013។

3/ ចូលជាធរមាន ថ្ងៃទី 1 ខែ កុម្ភៈ ឆ្នាំ 2014។

4/ ផ្អែកលើក្រសួងពាណិជ្ជកម្ម រាប់តែរោងចក្រកំពុងដំណើរការប៉ុណ្ណោះ។ ទិន្នន័យនេះ មិនរាប់បញ្ចូលនិយោជិតការិយាល័យបរទេស និង អ្នកគ្រប់គ្រងបរទេសទេ។

5/ ជាតម្លៃ ខែ ធ្នូ ឆ្នាំ 2010។

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងពាណិជ្ជកម្ម, ធនាគារជាតិនៃកម្ពុជា, មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) និង ការគណនារបស់បុគ្គលិកអង្គការអន្តរជាតិខាងការងារ។

## ព័ត៌មានទំនាក់ទំនង

ការិយាល័យអង្គការអន្តរជាតិខាងការងារ (ILO) ប្រចាំកម្ពុជា
ភ្នំពេញសិនធីរ អាគារ F ជាន់ទី 2
កាច់ជ្រុងមហាវិថីព្រះសីហនុ (274) និង មហាវិថីសុធារស (3)
រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: +855 23 220 817
Internet: www.ilo.org/asia
Email: huot@ilo.org

រក្សាសិទ្ធិ © អង្គការអន្តរជាតិខាងការងារ ឆ្នាំ 2015

*ព្រឹត្តិបត្រនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីដែលត្រូវបានគាំទ្រហិរញ្ញវត្ថុដោយអង្គការ GiZ តាងនាមឲ្យរដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់។ កម្មវិធីនេះ ត្រូវបានផ្តួចផ្តើមជាផ្នែកមួយនៃភាពជាដៃគូជាថ្មីមួយរវាងក្រសួងសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍អាល្លឺម៉ង់ (BMZ) និង អង្គការអន្តរជាតិខាងការងារ (ILO) ។ ការទទួលខុសត្រូវលើយោបល់ទាំងឡាយដែលត្រូវបានសម្តែងក្នុងព្រឹត្តិបត្រនេះ គឺស្ថិតទាំងស្រុងលើអ្នកនិពន្ធ ហើយការបោះពុម្ពផ្សាយព្រឹត្តិប័ត្រនេះ មិនមែនគឺជាការយល់ព្រមរបស់អង្គការអន្តរជាតិខាងការងារ ឬ រដ្ឋាភិបាលនៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ លើយោបល់ដែលត្រូវបានបង្ហាញនៅក្នុងព្រឹត្តិបត្រនេះទេ។*